ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ:...៣៧៧..ស.ណ...

ថ្ងៃជុំ...២២កើតខែអស្សុជ.....ឆ្នាំឆ្លូវ...ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.២៨.....ខែ.តុលា.....ឆ្នាំ ២០២១

សូមគោរពជូន
សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

កម្មវត្ថុ៖សំណើសុំកិច្ចសហការចាត់វិធានការចំពោះបុគ្គល និងម្ចាស់ហាងលក់វត្ថុសិល្បៈមានការទិញ-លក់វត្ថុបុរាណដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត។

យោង ៖-ព្រះរាជក្រម នស/រកម/២៦ ច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦។
-អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីអនុវត្តការពារបេតិកភណ្ឌវប្បធម៌។
-លិខិតលេខ១៥៣ ស.ណ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។
-លិខិតលេខ១០៨៨ ស.ណ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ស្របតាមគោលនយោបាយជាតិស្តីពី «**វិស័យវប្បធម៌**» ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានការកិច្ចក្នុងការថែរក្សាការពារ និងអភិរក្សសម្បត្តិវប្បធម៌ជាតិឱ្យបានគង់វង្ស។ នាពេលថ្មីៗនេះ ក្រសួងសង្កេតឃើញថាមានសកម្មភាពអវិជ្ជមានមួយចំនួនដូចជា ការលក់វត្ថុបុរាណតាមប្រព័ន្ធអេឡិចត្រូនិច ការលក់វត្ថុសិល្បៈមិនមានភាពស្មោះត្រង់ (លក់វត្ថុសិល្បៈផលិតថ្មី តែប្រាប់អ្នកទិញថាវត្ថុបុរាណ) ការលួចជីក និងបំផ្លាញស្ថានីយបុរាណដោយខុសច្បាប់ជាដើម។ ដូច្នេះ ដើម្បីចូលរួមថែរក្សាការពារសម្បត្តិបេតិកភណ្ឌសម្រាប់មនុស្សជំនាន់ក្រោយបានស្គាល់ និងបានសិក្សាស្រាវជ្រាវ ក្រសួងស្នើឱ្យ កងកម្លាំងនគរបាលការពារបេតិកភណ្ឌ ធ្វើជាកងកម្លាំងការពារយុត្តិធម៌ចំពោះគ្រប់ករណីដែលកើតមាននៅតាមបណ្តារាជធានី-ខេត្ត ក្នុងន័យទប់ស្កាត់ ការពារ ចាត់វិធានការ និងសហការរាល់ព័ត៌មានដែលទទួលបានដូចករណីខាងលើ។

ន័យដូចបានជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម** មេត្តាជ្រាប និងជួយអន្តរាគមន៍ដល់នគរបាលការពារបេតិកភណ្ឌ ដើម្បីចាត់វិធានការដល់ជនឬបុគ្គល និងហាងលក់វត្ថុសិល្បៈណាដែលបានទិញ-លក់វត្ថុបុរាណគ្រប់ប្រភេទដោយខុសច្បាប់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ។

ចម្លងជូន:
-ឧកញ៉ាលោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានបេតិកភណ្ឌ
"ដើម្បីជូនជ្រាប"
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី-ខេត្ត
"ដើម្បីសហការ អនុវត្ត"

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី
បណ្ឌិតសភាចារ្យ **ឡើង សកុណា**